**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ :...៣៧២ សជណ

ថ្ងៃ...ច័ន្ទ ១១ រោច.....ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី...១២.....ខែ..មីនា.........ឆ្នាំ២០១៨

**ជម្រាបមក**

**លោក អៀង សុផ្នី**

**ប្រធានអង្គការសមធម៌កម្ពុជា**

**<u>កម្មវត្ថុ</u>** ៖ ស្តីពីការអនុញ្ញាតឲ្យអង្គការសមធម៌កម្ពុជាធ្វើសកម្មភាពឡើងវិញ។

**<u>យោង</u>** ៖- ព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

- លិខិតលេខ ១៧៤៤ សជណ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការផ្អាកសកម្មភាពរបស់អង្គការសមធម៌កម្ពុជាជាបណ្តោះអាសន្ន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានអង្គការថា ក្រសួងមហាផ្ទៃ សម្រេចអនុញ្ញាតឲ្យអង្គការសមធម៌កម្ពុជាបន្តធ្វើសកម្មភាពរបស់ខ្លួនឡើងវិញ បន្ទាប់ពីអង្គការនេះបានបំពេញកាតព្វកិច្ចនានាដែលកំណត់តាមរយៈលិខិតលេខ ១៧៤៤ សជណ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ។

ទន្ទឹមនេះក្នុងការធ្វើសកម្មភាព អង្គការសមធម៌កម្ពុជាត្រូវតែអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាប និងចាត់ចែងអនុវត្តតាមស្មារតីខាងលើប្រកបដោយការទទួលខុសត្រូវ។

**ជ.រដ្ឋមន្ត្រី**

**ប៊ុន-ហុន**

**<u>ចម្លងជូន</u> ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធនាគារជាតិ នៃកម្ពុជា
- អាជ្ញាធរសវនកម្មជាតិ

"<u>ដើម្បីជូនជ្រាប</u>"

- សាលារាជធានីភ្នំពេញ និងគ្រប់សាលាខេត្ត
- អគ្គស្នងការដ្ឋាននគរបាលជាតិ

"<u>ដើម្បីមុខការ</u>"

- ឯកសារ - កាលប្បវត្តិ

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣

ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh